Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ភ្នំពេញ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីសេចក្តីសង្ខេបនៃរបាយការណ៍
# ស្តីពី
# ប្រជាធិបតេយ្យប្រចាំឆ្នាំ និងភាពមិនប្រក្រតីផ្នែកនយោបាយ

ប្រជាធិបតេយ្យរូបនីយកម្មនៅកម្ពុជាឆ្នាំ២០១៤ បានបន្តដំណើរទៅមុខយឺតៗ ជាមួយនឹងគុណវិបត្តិដ៏ច្រើនដែលជាឧបសគ្គ និងរារាំងដល់ជំហាននៃដំណើរឆ្ពោះទៅកាន់ប្រជាធិបតេយ្យដ៏ពិតប្រាកដមួយ។ ការវិវត្តន៍ជាវិជ្ជមានខាងបញ្ហានយោបាយត្រូវបានរកឃើញថា វាបានបង្កប់ជាមួយនូវភាពមិនប្រាកដប្រជាក្នុងកំរិតខ្ពស់ខ្លាំង។ វានៅមិនច្បាស់នៅឡើយទេថា តើជំហានការផ្លាស់ប្តូរខ្លះ និងលាយឡំជាមួយឧបសគ្គធំៗបែបនេះ អាចឲ្យដំណើរការប្រជាធិបតេយ្យត្រឡប់មកផ្លូវត្រូវឬយ៉ាងណានោះ។

ជម្លោះដែលកើតឡើង នៅក្រោយថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាតិឆ្នាំ២០១៣ និងវិបត្តិនយោបាយជាបន្តបន្ទាប់ បានក្លាយជាឧបសគ្គរាំងស្ទះដល់ដំណើរការអនុវត្តន៍របបប្រជាធិបតេយ្យនៅកម្ពុជាសារជាថ្មីម្តងទៀត។ សេរីភាពនៃការជួបជុំដោយសន្តិភាពត្រូវបានរាំងខ្ទប់យ៉ាងពេញទំហឹង។ ទើបតែមកដល់ថ្ងៃ២២ ខែកក្កដាឆ្នាំ២០១៤ ពោលគឺរយៈពេល១ឆ្នាំបន្ទាប់ការបោះឆ្នោតជាតិឆ្នាំ២០១៣ វិបត្តិនយោបាយត្រូវបានបញ្ចប់ ដោយកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយមួយ ដោយគណបក្សកាន់អំណាចជាមួយនឹងគណបក្សប្រឆាំង។ កិច្ចព្រមព្រៀងបញ្ចប់វិបត្តិនយោបាយនេះ បាននាំមកនូវដំណើរការកំណែទម្រង់ដែលបើកផ្លូវឲ្យសញ្ញាណសុទិដ្ឋិនិយមជាមួយការប្រុងប្រយ័ត្ននៃដំណើរការប្រជាធិបតេយ្យ។
បើទោះបីជាយ៉ាងនេះក្តី ការចូលរួមពីសាធារណជន និងដំណើរការចរចា រវាងគណបក្សប្រឆាំង និងគណបក្សកាន់អំណាច ជារឿយៗគេឃើញថា មានការបើកចំហ ជាពិសេស គឺកំណែទម្រង់ការបោះឆ្នោត និងស្ថាប័ននីតិបញ្ញត្តិ។ រហូតមកដល់ចុងឆ្នាំ២០១៤ ដំណើរការកំណែទម្រង់ការបោះឆ្នោតនៅតែស្ថិតនៅក្នុងភាពស្រពិចស្រពិលនៅឡើយ។ ការចរចាលើដំណើរការកំណែទម្រង់ការបោះឆ្នោត ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបន្តអូសបន្លាយមកដល់ឆ្នាំ២០១៥។ ចំណែកកំណែទម្រង់ស្ថាប័ននីតិបញ្ញត្តិ ក៏បានរំកិលបន្តរហូតមកដល់ដើមឆ្នាំ២០១៥ ផងដែរ។

ដំណើរការអនុវត្តន៍អភិបាលកិច្ចបែបប្រជាធិបតេយ្យ បានចេញជារូបរាងប្រសើរឡើងខ្លះ បន្ទាប់ពីមានកិច្ចព្រមព្រៀងនយោបាយនាខែកក្កដាមក។ កំណែទម្រង់ស្ថាប័ននីតិបញ្ញត្តិបានពង្រឹងគោលការណ៍បែងចែងអំណាច។ ស្ថាប័ននីតិបញ្ញត្តិបង្កើនឥទ្ធិពលរបស់ខ្លួន និងវិវត្តប្រសើរឡើងជាងមុននូវការអនុវត្តន៍តួនាទីនិងការងាររបស់ខ្លួន។ ក្នុងដំណាក់កាលកន្លះឆ្នាំមុនកិច្ចព្រមព្រៀងនយោបាយ គណបក្សសង្គ្រោះជាតិដែលជាគណបក្សប្រឆាំង មិនបានចូលរួមរួមក្នុងដំណើរការរបស់រដ្ឋសភាជាតិ ដូច្នេះជាផលវិបាក ស្ថាប័ន

**<u>ទីស្នាក់ការកណ្តាល</u>** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**<u>Central Office</u> : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**
**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

នីតិបញ្ញត្តិ និងនីតិប្រតិបត្តិ បានអនុវត្តតួនាទី និងការងាររបស់ខ្លួនក្នុងកំរិតមួយដែលមានដែនកំណត់យ៉ាងតូចចង្អៀត ហើយវាបានក្លាយជាបញ្ហានៃខ្វះភាពនិត្យានុកូលភាពនៃដំណើរការបង្កើតស្ថាប័ននីតិបញ្ញត្តិ និងការបង្កើតរាជរដ្ឋាភិបាលថ្មី ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា។ ស្ថាប័ននីតិប្រតិបត្តិនៅតែបន្តការអនុវត្តន៍គោលនយោបាយ និងការងាររបស់ខ្លួន ដោយខ្វះតម្លាភាព និងគណនេយ្យភាពដដែល។ ជាទូទៅ គេសង្កេតឃើញថា កំណែទម្រង់ប្រព័ន្ធយុត្តិធម៌របស់គណបក្សកាន់អំណាចនៅតែចោទជាបញ្ហាធំ និងបរាជ័យដែលមិនទាន់សម្រេចបាននូវការធានាឲ្យស្ថាប័នតុលាការឯករាជ្យនៅឡើយ។ ស្ថាប័នតុលាការនៅតែជាស្ថាប័នលាយឡំ ក្រោមឥទ្ធិពលគណបក្សនយោបាយ និងស្ថិតនៅក្នុងភាពទន់ខ្សោយ ដោយសារវាមានទំនាក់ទំនងជាមួយប្រព័ន្ធដឹកនាំទន់ខ្សោយរបស់រដ្ឋ។

ការបង្កើតគណៈកម្មការចម្រុះ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បង្ហាញឲ្យឃើញថា ជាជំហានកំណែទម្រង់ការបោះឆ្នោត ដែលធ្វើឡើងដោយទ្វេភាគីក៏ពិតមែន ប៉ុន្តែដំណើរការកំណែទម្រង់គឺធ្វើឡើងដោយខ្វះតម្លាភាព និងដោយគ្មានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗ។ កំណែទម្រង់សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវបានព្រមព្រៀង ដោយសមាជិករដ្ឋសភានៃគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា រួមទាំងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញផងដែរ។ កំណែទម្រង់សំខាន់ៗ ត្រូវបានចាប់ផ្តើមដំណើរការចរចានៅឆ្នាំ២០១៤ ក្នុងនោះរួមមានធ្វើសេចក្តីស្នើនៃពង្រាងសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពង្រាងច្បាប់សេចក្តីស្នើ ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរួមទាំងកំណែទម្រង់បញ្ជីចុះឈ្មោះបោះឆ្នោតនៅក្នុងនោះផងដែរ។ សេចក្តីស្នើពង្រាងច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានបញ្ចប់នៅចុងឆ្នាំ២០១៤។ ដំណើរការចរចាលើសេចក្តីព្រាងច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានបន្តរហូតមកដល់ឆ្នាំ២០១៥។

បើទោះបីជាគណបក្សជាប់ឆ្នោតទាំងពីរ បានសន្យាលើកិច្ចខិតខំប្រឹងប្រែងដើម្បី កែប្រែច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រយ៉ាងណាក្តី ប៉ុន្តែដំណើរការចរចា រវាងគណបក្សទាំងពីរលើសេចក្តីស្នើពង្រាងច្បាប់ គឺស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់ និងបានបង្កប់នូវមន្ទិលសង្ស័យជាច្រើន។ ច្បាប់ថ្មី អាចមានការផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត និងការបន្ថយរយៈពេលនៃការឃោសនាបោះឆ្នោត។ អ្វីជាការព្រួយបារម្ភដ៏ចំបងនោះ គឺ ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្មីនេះ បានដាក់បញ្ចូលបញ្ញត្តិលើការរិតបណ្តឹងសិទ្ធិ សេរីភាព របស់អង្គការសង្គមស៊ីវិល សមាគម និងគណបក្សនយោបាយប្រកួតប្រជែង ប៉ុន្តែបែរជាមានបញ្ញត្តិមួយចំនួនបានផ្តល់ភាពស្របច្បាប់ ដល់ការចូលរួមក្នុងសកម្មភាពលំអៀងនយោបាយនៃមន្ត្រីតុលាការ និងមន្ត្រីយោធា និងប៉ូលិសក្នុងអំឡុងពេលបោះឆ្នោតទៅវិញ។

ការរំលោភសិទ្ធិមនុស្ស ជាពិសេសទៅលើការរំលោភសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយរដ្ឋាភិបាល ត្រូវបានមើលឃើញក្នុងរូបភាពដ៏គួរឲ្យបារម្ភ។ លំហសេរីភាព និងប្រជាធិបតេយ្យនៅកម្ពុជាក្នុងឆ្នាំ២០១៤ គឺមិនការវិវត្តន៍ក្នុងរូបភាពវិជ្ជមាន ឬរីកចំរើនឡើយ។ រាជរដ្ឋាភិបាល ប្រើកំលាំងកងសន្តិសុខជ្រុលហួសហេតុ មិនសមាត្រ ដើម្បីប្រឆាំងនឹងអ្នកតវ៉ា ក្នុងអំឡុងពេលនៃការធ្វើបាតុកម្មនៅដើមឆ្នាំ២០១៤។ មានករណីបាញ់ប្រហារ ការចោទប្រកាន់ ការរំលោភបំពាន ការគំរាមកំហែង និងការបំភិតបំភ័យដោយ

ផ្ទាល់ទៅលើក្រុមសហជីព អ្នកកាសែត ជនស៊ីវិល និងសកម្មជនសិទ្ធិមនុស្ស និងគណបក្សនយោបាយ រួមទាំងអ្នកតំណាងរាស្ត្រជាប់ឆ្នោតនៃគណបក្សសង្គ្រោះជាតិ និងសមាជិក ឬមន្ត្រីរបស់គណបក្សក្នុងឆ្នាំ ២០១៤។ កំដៅអំពើហិង្សា បានចាប់ផ្តើមចេញពីការបាញ់សម្លាប់ក្រុមកម្មកររោងចក្រដែលធ្វើបាតុកម្ម ហើយបានធ្វើឲ្យបាត់បង់ជីវិតយុជន៤នាក់ ដោយកងកម្លាំងយោធានៅក្នុងខែមករា។ អ្នកកាសែតពីរនាក់ ត្រូវបានគេធ្វើឃាតនៅឆ្នាំ២០១៤។ ការបង្រ្កាប ឬការដាក់សម្ពាធនេះ បានប្រែក្លាយជាលេសក្នុងការគម្រាមកំហែង និងបំភិតបំភ័យទៅលើប្រជាពលរដ្ឋស៊ីវិល ដែលជាអ្នកគាំទ្រគណបក្សប្រឆាំង និងក្រុមអ្នកហ៊ានរិះគន់ប្រឆាំងនឹងរដ្ឋាភិបាលកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា។ គ្មានវិធានការណាមួយត្រូវបានដាក់ចេញ ដើម្បីទប់ស្កាត់ទៅលើកងកំលាំងរក្សាសន្តិសុខដែលប្រើកំលាំង និងប្រដាប់ដោយអាវុធ និងទង្វើហួសហេតុ មិនសមាមាត្រ មកលើក្រុមបាតុករឡើយ។

ក្រោយពីកិច្ចព្រមព្រៀងថ្ងៃទី២២ ខែកក្កដា ត្រូវបានដោះស្រាយរួចរាល់ទៅ គេសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជា មិនបានបើកចំហនូវលំហប្រជាធិបតេយ្យ ដើម្បីបើកផ្លូវឲ្យមានការជួបជុំដោយសន្តិភាព និងការសំដែងមតិវិញឡើយ។ លើកលែងតែករណីមួយដែលគេសង្កេតឃើញថា មានការប្រសើរជាងមុនបន្តិចបន្តួច គឺការសន្យារបស់រដ្ឋាភិបាល ថានឹងយល់ព្រមផ្តល់អាជ្ញាប័ណ្ណប៉ុស្តិ៍ទូរទស្សន៍ និងវិទ្យុទៅក្រុមហ៊ុននៃគណបក្សសង្គ្រោះជាតិនៅក្នុងខែវិច្ឆិកា ដើម្បីឲ្យមានតុល្យភាពគ្នា រវាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ស្ថានីយ៍ទូរទស្សន៍ និងវិទ្យុទាំងពីរនេះនឹងផ្សាយចេញពីរាជធានីភ្នំពេញ ហើយអាចផ្សាយបន្តនៅតាមខេត្តផ្សេងៗក្នុងប្រទេស។

ការរៀបចំបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី និងសមាភាពថ្មីរបស់វា នឹងត្រូវសម្រេចធ្វើឡើង ដោយគណបក្សទាំងពីរក្រុម (គណបក្សដឹកនាំដោយរដ្ឋាភិបាល និងគណបក្សប្រឆាំង) ដែលមានអាសនៈក្នុងរដ្ឋសភា។ រដ្ឋសភាក៏នឹងត្រូវអនុម័តការផ្លាស់ប្តូរសំខាន់ចំនួន២៤បញ្ញត្តិនៃសេចក្តីស្នើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ មាន១៥បញ្ញត្តិត្រូវបានកត់សំគាល់ថា ជាការផ្លាស់ប្តូរវិជ្ជមាន ឬអាចចាត់ទុកថាវាជាចំណុចផ្លាស់ប្តូរដែលប្រសើរជាមុន និងមាន៩បញ្ញត្តិផ្សេងទៀត ជាចំណុចអវិជ្ជមាន ឬមិនច្បាស់លាស់ ឬអាក្រក់ជាងច្បាប់ចាស់។ អ្វីដែលជាកង្វល់ដ៏ធំនៃកំណែទម្រង់ការបោះឆ្នោតដោយទ្វេភាគី គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ថាតើនឹងឆ្លើយតប ឬធ្វើយ៉ាងណាចំពោះលទ្ធផលនៃការបោះឆ្នោត ប្រសិនបើជាមានការផ្លាស់ប្តូរគណបក្សដឹកនាំរដ្ឋាភិបាល ឬថា គណបក្សប្រជាជននៅតែបន្តឈ្នះការបោះឆ្នោត និងដឹកនាំប្រទេសដដែល។

ក្នុងរយៈកាលកន្លងទៅ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ហាក់ដូចជាគ្រាន់តែបានបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឲ្យបន្តការគាំទ្របោះឆ្នោតឲ្យគណបក្សរបស់ខ្លួននៅឆ្នាំ២០១៧ និងឆ្នាំ២០១៨ ខាងមុខប៉ុណ្ណោះ។ ប៉ុន្តែពួកគេមិនបានពិចារណាឲ្យបានល្អិតល្អន់ទៅលើបញ្ហា ថាតើត្រូវធ្វើយ៉ាងម៉េច នៅពេលដែលពួកគេចាញ់ការបោះឆ្នោត។ ខណៈពេលដែលមានកំណែទម្រង់ការបោះឆ្នោតមួយចំនួនធំ ត្រូវបានធ្វើឡើង និងការបង្កើតវប្បធម៌ដែគូសន្ទនា រវាងមេដឹកនាំក្រុមតំណាងរាស្ត្រភាគតិច និងមេដឹកនាំក្រុមតំណាងរាស្ត្រគណបក្សកាន់អំណាច ទំនងជាកត្តាមួយជួយជម្រុញឲ្យគណបក្សនយោបាយ ឈានទៅដល់ការទទួលយកលទ្ធនៃការបរាជ័យក្នុងការបោះឆ្នោតនាពេលអនាគត ប៉ុន្តែដំណើរការកំណែទម្រង់

ទាំងនេះកំពុងស្ថិតនៅក្នុងភាពមិនប្រាកដប្រជា និងបានបង្កើតជាចម្ងល់លើបញ្ហានៃការទទួលយកលទ្ធផល ទាំងលទ្ធផលបរាជ័យ និងជោគជ័យ។ បើក្រឡេកទៅមើលបទពិសោធន៍ដែលធ្លាប់ឆ្លងកាត់កន្លងមក គណបក្សនយោបាយដែលចាញ់ឆ្នោត គឺទំនងជានឹងមិនទទួលយកលទ្ធផលបរាជ័យរបស់ខ្លួន។ បច្ចុប្បន្ននេះ មិនទាន់មានព័ត៌មាន ឬសញ្ញាណណាមួយទាក់ទងទៅនឹងផែនការរបស់រដ្ឋាភិបាល ដើម្បីជួយធានាឲ្យច្បាស់លាស់ដល់ការផ្ទេរអំណាចដោយសន្តិភាព ប្រសិនបើនៅឆ្នាំ២០១៨ខាងមុខ ពិតជាមានការផ្លាស់ប្តូរគណបក្សដឹកនាំរដ្ឋាភិបាលពិតមែននោះនៅឡើយទេ។

របាយការណ៍បានរកឃើញនូវភាពប្រសើរឡើង លើសកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយរបស់រដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០១៤នេះ។ ប៉ុន្តែបើទោះជាយ៉ាងនេះក្តី អំពើពុករលួស និងការប្រើប្រាស់ធនធានរដ្ឋ ដើម្បីបម្រើផលប្រយោជន៍នយោបាយ នៅតែចាក់ឫសយ៉ាងមាំនៅឡើយ និងជាប្រព័ន្ធ។ ភាពទន់ខ្សោយបន្តឱ្យមានករណីប្រើប្រាស់ធនធាន ឬទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីបម្រើផលប្រយោជន៍គណបក្សនយោបាយ ការចូលជាមន្ត្រីគណបក្សនយោបាយ និងលំអៀងនយោបាយនៃមន្ត្រីតុលាការ និងមន្ត្រីកងកម្លាំងប្រដាប់អាវុធ ដែលបំពេញតួនាទីបម្រើផលប្រយោជន៍គណបក្សកាន់អំណាច គឺនៅតែបន្តកើតមានស្ទើរតែក្លាយទម្លាប់ទូទៅទៅហើយ។ តាមរយៈការសិក្សា ខុមហ្វ្រែលរកឃើញថា ករណីភាពមិនប្រក្រតីសំណូកដោយមន្ត្រីសាធារណៈក្នុងតំណែង គឺមាន១៣១ករណី។ ក្នុងចំណោម១៣១ករណីនេះ មាន៦០ករណីពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ហើយមានចំនួន៣ករណីត្រូវបានរកឃើញថាជាករណីរំលោភអំណាច និង១៨ករណីផ្សេងទៀត ជាបញ្ហាពាក់ព័ន្ធនឹងបញ្ហាខ្សែស្រឡាយ សាច់ញាតិនិយម និងចុងក្រោយ គឺភាពមិនប្រក្រតីសំណូកដោយមន្ត្រីនយោបាយមាន៥ករណី។

ករណីនៃការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ បម្រើឱ្យគណបក្សនយោបាយចំនួន៦០ករណី ដែលបានកត់ត្រាខាងលើ ក្នុងនោះរួមមាន ករណីនៃការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ ដូចជាការចូលរួមពីសំណាក់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិល និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ក្នុងការធ្វើសកម្មភាពប្រឆាំង ឬគាំទ្រចំពោះគណបក្សនយោបាយ និងថ្នាក់ដឹកនាំគណបក្សផ្សេង។ ជាទូទៅការសង្កេតឃើញប្រព័ន្ធផ្សព្វផ្សាយរដ្ឋ បានផ្សព្វផ្សាយព័ត៌មានលំអៀងទៅរកគណបក្សកាន់អំណាច ដូចជាជួយផ្សព្វផ្សាយអំពីសកម្មភាពរបស់រដ្ឋាភិបាល ដោយបញ្ចូលនូវគោលនយោបាយរបស់គណបក្សកាន់អំណាច អំពីជំហររបស់អ្នកគាំទ្រគណបក្សកាន់អំណាច និងភាគច្រើន គឺលើកពីផលអវិជ្ជមានប្រឆាំងនឹងសកម្មភាពមេដឹកនាំគណបក្សប្រឆាំងជាដើម។ មានទាំងការផ្សព្វផ្សាយអំពីវិធានការរបស់រដ្ឋាភិបាល និងការប្រើប្រាស់ប្រព័ន្ធច្បាប់ប្រឆាំងនឹងគណបក្ស ឬក្រុមប្រឆាំង។

មានករណីរំលោភ ឬបំពានអំណាចច្រើនករណីផ្សេងទៀត ដែលប្រព្រឹត្តដោយមន្ត្រីរដ្ឋាភិបាល និងអាជ្ញាធរសាធារណៈ ដើម្បីបម្រើផលប្រយោជន៍នយោបាយ ដូចជាករណីចេញលិខិត បទបញ្ជាដែលលើសពីច្បាប់កំណត់ ឬដោយមិនបានផ្អែកលើគោលការណ៍មូលដ្ឋានគតិយុត្តិ និងធម្មនុញ្ញភាពនៃច្បាប់។ មានករណីមិនប្រក្រតីផងដែរ លើការដាក់បញ្ចូល ឬតែងតាំងសាច់ញាតិព័ន្ធ កូន ប្តី ប្រពន្ធនៃអ្នកនយោបាយ ឬសមាជិកគណបក្សនយោបាយ ត្រូវបានធ្វើឡើង ដោយមិនគោរពតាមនីតិវិធីដែលតម្រូវដោយច្បាប់ និងខ្វះតម្លាភាព។

ស្ថានភាពតម្លាភាពនៃការគ្រប់គ្រងថវិកាជាតិនៅកម្ពុជា គឺនៅមានកម្រិតទាបខ្លាំងនៅឡើយ។ ដូចគ្នាទៅនឹងឥរិយាបទរដ្ឋាភិបាលអាណត្តិមុនៗដែរ រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥នេះ មិនបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ ល្អិតល្អន់ដល់សាធារណជន និងអ្នកតំណាងរាស្ត្រ ឬរបាយការណ៍លម្អិតអំពីថវិកាជាតិ និងសកម្មភាពចំណាយ ចំណូលហិរញ្ញវត្ថុរបស់ស្ថាប័នរដ្ឋ ក្រសួង។ ករណីទាំងនេះ វាពិតជាបានកើតឡើងយ៉ាងពិតប្រាកដ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ កត្តានេះបានបង្កការលំបាកដល់ប្រជាពលរដ្ឋ អ្នកសារព័ត៌មាន អ្នកស្រាវជ្រាវ និងអ្នកតំណាងរាស្ត្រ ជាពិសេសសមាជិករដ្ឋសភារបស់គណបក្សប្រឆាំងក្នុងការតាមដានការចាយវាយរបស់រាជរដ្ឋាភិបាល។

ទិន្នន័យបានពីការស្រាវជ្រាវនេះ គឺត្រូវបានដាក់បញ្ចូលសម្រាប់របាយការណ៍ពីរ។ របាយការណ៍ទី១ គឺជារបាយការណ៍ស្តីអំពីប្រជាធិបតេយ្យនៅកម្ពុជាឆ្នាំ២០១៤ ដែលរៀបចំឡើងដោយផ្អែកលើការរកឃើញក្នុងរបាយការណ៍ឃ្លាំមើលរដ្ឋាភិបាល របាយការណ៍ឃ្លាំមើលសភា របាយការណ៍ឃ្លាំមើលប្រព័ន្ធផ្សព្វផ្សាយ របាយការណ៍ឃ្លាំមើលការបោះឆ្នោត របាយការណ៍ ស្តីពីការឃ្លាំមើលយេនឌ័រក្នុងកិច្ចការនយោបាយ ក្រុមការងារសង្គមស៊ីវិល ស្តីពីសិទ្ធិនៃការទទួលបានព័ត៌មាន និងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត។ ជាមួយគ្នានេះផងដែរ ខុមហ្វ្រែល បានប្រើវិធីសាស្ត្រស្រាវជ្រាវពីរប្រភេទ គឺទាំងវិធីសាស្ត្រស្រាវជ្រាវវិភាគបែបបរិមាណ និងវិធីសាស្ត្របែបគុណភាព (Quantitative and Qualitative research methods)។ ការវិភាគលើរបាយការណ៍ ក៏បានភ្ជាប់ដោយការប្រៀបធៀបផងដែរ ជាមួយនឹងស្ថានភាពនយោបាយដែលបានកើតឡើងក្នុងឆ្នាំមុនៗ។ សូចនាករប្រជាធិបតេយ្យ រួមមាន អភិបាលកិច្ចបែបប្រជាធិបតេយ្យ ការបោះឆ្នោតបែបប្រជាធិបតេយ្យ និងលំហប្រជាធិបតេយ្យ និងសេរីភាព។ របាយការណ៍នេះផ្តោតផងដែរលើការអនុវត្តន៍អំណាច ការបំពេញ និងកំណែទម្រង់ស្ថាប័ននីតិបញ្ញត្តិ តុលាការ និងស្ថាប័ននីតិប្រតិបត្តិ។ របាយករណ៍ក៏បានផ្តោតសំខាន់ គឺដំណើរការវិវត្តន៍នៃស្ថានការណ៍ក្រោយ វិបត្តិនយោបាយ ដែលបានកើតឡើងនៅក្រោយថ្ងៃបោះឆ្នោត។ របាយការណ៍មួយទៀត ស្តីអំពីភាពមិនប្រក្រតីខាងនយោបាយមានជាភាសាខ្មែរ ដោយធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកលើព័ត៌មាន ឬទិន្នន័យដែលមានស្រាប់ ដូចជាទិន្នន័យ ឬព័ត៌មានដែលបានមកពីរបាយការណ៍របស់ខុមហ្វ្រែល និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗជាដើម។ របាយការណ៍នេះ គឺជាការចងក្រងព័ត៌មាន ស្តីពីការបំពាន ការប្រើប្រាស់ធនធានរដ្ឋ ដើម្បីបម្រើផលប្រយោជន៍នយោបាយ និងអំពើពុករលួយទាក់ទិននយោបាយ ដែលរួមមានការបំពានអំណាច និងបក្សពួកនិយមបែបនយោបាយនៅកម្ពុជា។

**ទំនាក់ទំនង៖**

១. លោក គល់ បញ្ញា — នាយកប្រតិបត្តិ អង្គការខុមហ្វ្រែល
ទូរស័ព្ទលេខ៖ (+855) 12 94 20 17, kpanha@comfrel.org

២. លោក យឿង សុធារ៉ា — មន្ត្រីផ្នែកច្បាប់ និងអង្កេត (ខុមហ្វ្រែល)
ទូរស័ព្ទលេខ៖ (+855) 12 38 00 85, sotheara@comfrel.org

៣. លោក ប្លង បឿត — មន្ត្រីជាន់ខ្ពស់ផ្នែកបណ្តាញ (ខុមហ្វ្រែល)
ទូរស័ព្ទលេខ៖ (+855) 12 47 13 26, boeurth@comfrel.org

របាយការណ៍ពិស្តារមាននៅ : www.comfrel.org